ខេមបូឌា ស៊ីឃ្យូរីធី
柬埔寨证券
CAMBODIA SECURITIES

Picasso
PICASSO CITY GARDEN DEVELOPMENT PLC
(PCG)

*ថ្ងៃអង្គារ ៦ កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៥*

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបន្តបន្ថែមពេលវេលានៃការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលបោះផ្សាយលក់ជាសាធារណៈលើកដំបូងរបស់ ក្រុមហ៊ុន ពីកាស្សូ ស៊ីធី ហ្គាឌិន ឌីវេឡុបមិន ម.ក

ក្រុមហ៊ុន **ខេមបូឌា ស៊ីឃ្យូរីធី ម.ក** ( "ក្រុមហ៊ុន" ) ក្នុងនាមជាទីប្រឹក្សាហិរញ្ញវត្ថុ និងជាក្រុមហ៊ុនធានាទិញមូលបត្ររបស់ក្រុមហ៊ុន **ពីកាស្សូ ស៊ីធី ហ្គាឌិន ឌីវេឡុបមិន ម.ក** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន វិនិយោគិនដែលបាន និងមានបំណងចូលរួមក្នុងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដែលបោះផ្សាយលក់ជាសាធារណៈលើកដំបូង និងភាគីពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបថា៖ ដើម្បីឆ្លើយតបនឹងតម្រូវការ ជាក់ស្តែងរបស់វិនិយោគិននិងភាពចាំបាច់របស់ក្រុមហ៊ុនដើម្បីធានាថាការធ្វើបរិវិសកម្មនេះដំណើរការទៅដោយរលូន និងប្រកបដោយប្រសិទ្ធភាពខ្ពស់កាលបរិច្ឆេទឈប់ទទួលពាក្យស្នើសុំធ្វើបរិវិសកម្ម នឹងត្រូវ បន្តរហូតដល់ **ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៥** វេលាម៉ោង ៥:០០ នាទីរសៀល ( ម៉ោងនៅព្រះរាជាណាចក្រ កម្ពុជា )។

សម្រាប់លក្ខខណ្ឌនានា សម្រាប់ការចូលរួមធ្វើការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលបោះផ្សាយលក់របស់ ក្រុមហ៊ុន **ពីកាស្សូ ស៊ីធី ហ្គាឌិន ឌីវេឡុបមិន ម.ក** នៅរក្សាទុកមិនមានការផ្លាស់ប្តូរ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់ក្រុមហ៊ុនដោយផ្ទាល់ តាមរយៈទូរស័ព្ទ 023 997 888 និង 015 997288។

សូម សាធារណជន វិនិយោគិន និងភាគីពាក់ព័ន្ធនានា មេត្តាជ្រាបជាព័ត៌មាន។

**ក្រុមហ៊ុន ខេមបូឌា ស៊ីឃ្យូរីធី ម.ក**
CAMBODIA SECURITIES PLC.

ក្រុមហ៊ុន ខេមបូឌា ស៊ីឃ្យូរីធី ម.ក
CAMBODIA SECURITIES PLC.
KINGDOM OF CAMBODIA

29th Floor, Room 2902 of Building No. 41, Street 360, Phum 7, Sangkat Toul Svay Prey 1, Khan Boeung Keng Kang, Phnom Penh, Cambodia.
www.cambodiasecurities.com.kh
+855 23 997 888